**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០២៩៨ ស ណ ន

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ តុលា ឆ្នាំ២០០៩

# សេចក្ដីណែនាំ
# ស្ដីពី
# ទីកន្លែងហាមជក់បារី

យោងតាមខ្លឹមសារ នៃលិខិតរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីលេខ១២៧០ សជណ.អរ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ១៩៩៤ ស្ដីពីគោលការណ៍ហាមជក់បារី នៅក្នុងកន្លែងធ្វើការរបស់មន្ត្រីរាជការ សាលប្រជុំ រោងមហោស្រព និងយោងតាម ស្មារតីអង្គសិក្ខាសាលា កាលពីថ្ងៃទី ១៤-១៧-១៨-២១ ខែកញ្ញា ឆ្នាំ២០០៧ ដែលបានបង្ហាញឱ្យឃើញអំពីផលវិបាក នៃ ការជក់បារី និងស្រូបបារីពីអ្នកជក់ ដែលបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ដល់សុខភាពសាធារណជន បរិស្ថាន ធ្វើឱ្យបាត់បង់ ថវិកាគ្រួសារ និងសេដ្ឋកិច្ចជាតិទៀតផង ។

ដើម្បីអនុវត្តឱ្យស្របទៅនឹងខ្លឹមសារនៃលិខិតរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងស្មារតីនៃអង្គសិក្ខាសាលាខាងលើ ក៏ដូចជាការចូលរួមលើកកំពស់ក្នុងការការពារនូវផលប៉ះពាល់ទាំងឡាយដែលកើតចេញពីការជក់ និងស្រូបផ្សែងបារីពីអ្នកជក់ ។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់មន្ត្រីរាជការ និងនគរបាល ក្នុងទីស្ដីការក្រសួងមហាផ្ទៃដូចខាងក្រោម:

១- ហាមជក់បារី នៅក្នុងអគារធ្វើការ បន្ទប់ធ្វើការរបស់មន្ត្រីរាជការ នគរបាល ក្នុងទីស្ដីការក្រសួង និងតាម ផ្លូវដើរចេញ-ចូល នៃអគារធ្វើការរបស់មន្ត្រីរាជការ និងនគរបាល ។

២- ទីកន្លែងខាងលើនេះត្រូវអនុវត្តដូចតទៅ :

- បិទផ្លាកហាមជក់បារី
- បិទរូបភាពផ្សព្វផ្សាយ អប់រំស្ដីពីផលប៉ះពាល់ដល់សុខភាព ដោយការជក់បារី
- ត្រូវចូលរួមធ្វើការអប់រំ ស្ដីពីផលប៉ះពាល់សុខភាព ដោយការប្រើប្រាស់ថ្នាំជក់ ដើម្បីទប់ស្កាត់ ឬកាត់ បន្ថយការជក់បារី រហូតឈានដល់ការលះបង់ទម្លាប់ជក់បារីទាំងស្រុង ។

៣- ក្នុងករណីមានការប្រព្រឹត្តផ្ទុយ ពីសេចក្ដីណែនាំ ដែលបានរៀបរាប់ខាងលើ ត្រូវទទួលការណែនាំពីប្រធាន អង្គភាពសាមី ។

ពេលទទួលបានសេចក្ដីណែនាំនេះ ឯកឧត្តមថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល អគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកដ្ឋានភ័ស្ដុភារ និងហិរញ្ញវត្ថុ និងមន្ត្រីរាជការទាំងអស់ក្រោមឱវាទក្រសួងមហាផ្ទៃ ត្រូវអនុវត្តតាមសេចក្ដីណែនាំ ខាងលើឱ្យមានប្រសិទ្ធភាព ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**ចម្លងជូន:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
- អង្គការក្រៅរដ្ឋាភិបាលពាក់ពន្ធ័
- មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ